# សុវណ្ណកក្កដកជាតក[១]




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធស្រ្តីម្នាក់ បានត្រាស់ព្រះធម្ម-ទេសនានេះ មានពាក្យថា* **សិង្គី មិគោ** *ដូច្នេះ (ជាដើម) ។*

*បានឮមកថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈ (គ្រួស្តី) ម្នាក់បាននាំភរិយារបស់ខ្លួនទៅកាន់ជនបទ ដើម្បីត្រូវការជម្រះបំណុល (ទារបំណុល) ឲ្យអស់ ។ ពេលជម្រះបំណុលអស់ហើយ ក៏ដើរផ្លូវមកវិញ ហើយត្រូវពួកចោរចាប់បានក្នុងរវាងផ្លូវ ។ ភរិយារបស់គ្រួស្តីនោះជាស្រ្តីមានរូបស្អាតគួរជាទីស្រឡាញ់ ។ មេចោរប្រាថ្នានឹងសម្លាប់គ្រួស្តីនោះ ព្រោះសេចក្តីស្នេហាលើនាង តែនាងជាស្រ្តីមានសីល បរិបូរណ៍ដោយអាចារមារយាទ គោរពស្វាមីដូចទេវតា ។ នាងទើបក្រាបទៀបជើងរបស់មេចោរលន់តួអង្វរថា បពិត្រលោកចោរអើយ បើលោកមានសេចក្តីស្នេហាខ្ញុំ លោកកុំសម្លាប់ស្វាមីរបស់ខ្ញុំអី បើលោកសម្លាប់គាត់ ខ្ញុំនឹងផឹកថ្នាំពិស ឬអត់ដង្ហើមឲ្យស្លាប់ ខ្ញុំ*

---

*១. ច្បាប់ឆដ្ឋសង្គាយនាថា កក្កដកជាតក ។*

នឹងមិនទៅជាមួយលោកទេ លោកកុំសម្លាប់ស្វាមីរបស់ខ្ញុំដោយហេតុនេះឡើយ ហើយនាងបានសូមឲ្យដោះលែងស្វាមីនោះ ។

ចំណែកស្វាមីភរិយាទាំងពីរនោះ បានទៅដល់ក្រុងសាវត្ថីដោយផុតភ័យ ដើរផ្លូវមកតាមខាងក្រោយវិហារជេតពន ក៏ចូលទៅកាន់វិហារ ផឹកទឹកហើយ និយាយគ្នាថា យើងនឹងថ្វាយបង្គំព្រះសាស្តា ទើបចូលទៅកាន់បរិវេណព្រះគន្ធកុដិ បានថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

ព្រះសាស្តាត្រាស់សួរស្វាមីភរិយាទាំងពីរនោះថា ម្នាលឧបាសកឧបាសិកាទាំងឡាយអ្នកទាំងឡាយទៅពីណា ?

គេទាំងពីរទើបក្រាបទូលថា ទៅដើម្បីប្រយោជន៍ដល់ការជម្រះបំណុល ។

កាលព្រះសាស្តាត្រាស់ថា ក្នុងរវាងផ្លូវ ពួកអ្នកមកដោយមិនមានរោគទេឬ ?

ភ្ញុម្ពីទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងរវាងផ្លូវ ពួកចោរបានចាប់ខ្ញុំព្រះអង្គទាំងពីរ ក្នុងពេលនោះ ភរិយារបស់ខ្ញុំព្រះអង្គនេះបានសូមអង្វរមេចោរ ដែលប្រាថ្នានឹងសម្លាប់ខ្ញុំព្រះអង្គ ឲ្យរួចខ្លួន ព្រោះអាស្រ័យភរិយានេះ ខ្ញុំព្រះអង្គទើបមានជីវិត ។

ព្រះសាស្តាត្រាស់ថា ម្នាកឧបាសក មិនមែនតែឥឡូវនេះទេ ដែលស្ត្រីនេះបានឲ្យជីវិតដល់លោក សូម្បីក្នុងកាលមុន ស្ត្រីនេះក៏បានឲ្យជីវិតដល់បណ្ឌិតទាំងឡាយដែរ ។ ព្រះអង្គត្រូវភ្ញុម្ពីនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកជាសាធកៈ ដូចទៅថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ។ ក្នុងព្រៃហិមពាន្តមានស្រះធំដ៏ជ្រៅមួយ ។ ក្នុងស្រះធំនោះ មាន**សុវណ្ណកក្កដកៈ** (ក្តាមពណ៌មាស) ធំអាស្រ័យនៅ ។ ស្រះធំនោះបានប្រាកដឈ្មោះថា **កុឡីររហទៈ** ប្រែថា **បឹងក្តាម** ព្រោះជាទីនៅ

របស់ក្ដាមមាសនោះ ។ ក្ដាមមាសនោះមានប្រមាណប៉ុនលានស្រូវ តែងចាប់ដំរីស៊ី ព្រោះខ្លាចក្ដាមមាសនោះ ដំរីទាំងឡាយមិនអាចនឹងចុះស្រះទឹកនោះស្វែងរកអាហារឡើយ ។

ក្នុងកាលនោះ ព្រះពោធិសត្វកាន់យកបដិសន្ធិក្នុងផ្ទៃនៃមេដំរីមួយ ដែលអាស្រ័យនឹងប្រធាននៃហ្វូងដំរីទាំងឡាយដែលនៅអាស្រ័យនឹងស្រះក្ដាមនោះ ។ គ្រានោះ មាតារបស់ព្រះពោធិសត្វគិតថា យើងនឹងរក្សាគភ៌ ទើបទៅកាន់ភ្នំដទៃមួយ ហើយរក្សានូវគភ៌ និងបានប្រសូតនូវកូនដំរីមួយ ។

ព្រះពោធិសត្វនោះចម្រើនវ័យធំឡើងជាលំដាប់ហើយ ជាអ្នកមានបរិវារច្រើន បរិបូណ៌ដោយកម្លាំង និងជាអ្នកក្រៃលែងដោយភាពស្អាត ហាក់បីដូចជា ភ្នំអញ្ជន ។ ព្រះពោធិសត្វបាននៅរួមជាមួយនឹងដំរីញីមួយ ហើយគិតថា យើងនឹងចាប់ក្ដាម ទើបនាំកិរិយានិងមាតារបស់ខ្លួនចូលទៅក្នុងហ្វូងដំរីនោះ និងជួបបិតារបស់ខ្លួន ហើយនិយាយថា បពិត្រលោកឪពុកខ្ញុំនឹងចាប់ក្ដាម ។

លំដាប់នោះ បិតារបស់ព្រះពោធិសត្វពោលហាមថា នែកូន ! អ្នកមិនអាចទេ កាលពោលហាមដូច្នេះរឿយៗហើយទើបពោលទៀតថា អ្នកនឹងដឹងដោយខ្លួនឯងចុះ ។

ព្រះពោធិសត្វនោះ បានឲ្យដំរីទាំងអស់ដែលអាស្រ័យនឹងស្រះក្ដាមមកប្រជុំគ្នា ហើយទៅកាន់ទីជិតស្រះនោះ និងបានសួរថា ក្ដាមនោះ ចាប់ដំរីក្នុងពេលដែលចុះ ឬ ក្នុងពេលដែលដំរីស្វែករកអាហារ ឬ ក្នុងពេលឡើងមកវិញ កាលបានស្ដាប់ថា ក្នុងពេលដែលឡើងមកវិញដូច្នេះ ទើបពោលថា ព្រោះហេតុនោះ អ្នកទាំងឡាយចូរចុះស្រះក្ដាម ហើយកាន់យកអាហារដរាបគ្រប់គ្រាន់ ហើយចូរនាំគ្នាឡើងមកមុនចុះ យើងនឹងជាអ្នកនៅក្រោយគេ ។ ដំរីទាំងឡាយក៏បានធ្វើយ៉ាងនោះ ។

*ក្តាមជាអ្នកពិឃាតបានចាប់ព្រះពោធិសត្វ ដែលជាអ្នកកំពុងឡើងក្រោយគេ ដោយតង្កៀបទាំងពីរយ៉ាងមាំ ហាក់បីដូចជាស្ទាកដែក ។ ដំរីទាំងឡាយមិនលះបង់ព្រះពោធិសត្វ ហើយបិតនៅក្នុងទីជិតនោះឯង ។ ព្រះពោធិសត្វមិនអាចនឹងធ្វើក្តាមឲ្យកម្រើកឡើយ ចំណែកក្តាមកាលទាញព្រះពោធិសត្វ ធ្វើឲ្យនៅនឹងមាត់របស់ខ្លួន ។ ព្រះពោធិសត្វនោះ ត្រូវមរណភ័យគ្របសង្កត់ហើយ ទើបស្រែកឡើងជាប់បន្តគ្នា ។ ដំរីទាំងអស់ ជាអ្នកដល់នូវមរណភ័យ បានធ្វើនូវកោញ្ចនាទ បេញអាចម៍បេញនោម នាំគ្នាបោលរត់ទៅ ។ សូម្បីមេដំរីដែលជាភរិយារបស់ព្រះពោធិសត្វក៏មិនអាចនឹងបិតនៅ ហើយប្រារព្ធនឹងរត់ទៅ ។*

*លំដាប់នោះ ព្រះពោធិសត្វបានញ៉ាំងមេដំរីនោះឲ្យដឹងថា ខ្លួនត្រូវកៀបជាប់ ដើម្បីនឹងមិនឲ្យនាងគេចទៅ ទើបពោលគាថាទីមួយ ថា*

**សិង្គីមិគោ អាយតចក្ខុនេត្តោ, អដ្ឋិត្តចោ វារិសយោ អលោមោ;**

**តេជាភិភូតោ កបណំ រុទាមិ, មា ហេវ មំ ចាណសមំ ជហេយ្យ ។**

***ម្រឹគមានសម្បុរដូចមាស ជាសត្វមានភ្នែកលៀនវែង មានឆ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម យើងត្រូវក្តាមនោះថ្កៀបហើយ ទើបកម្សត់ទួញយំ សូមភរិយាកុំលះបង់នូវបងដែលស្មើដោយជីវិតឡើយ ។***

*លំដាប់នោះ មេដំរីបានត្រឡប់មកវិញ កាលលួងលោមព្រះពោធិសត្វ ទើបពោលគាថាទីពីរថា*

**អយ្យ ន តំ ជហិស្សាមិ, កុញ្ជរំ សដ្ឋិហាយនំ;**
**បថព្យា ចាតុរន្តាយ, សុប្បិយោ ហោសិ មេ តុវំ។**

*បពិត្រអ្នកជាម្ចាស់ ខ្ញុំមិនបានលះបង់អ្នកដែលជាដំរីថមថយកម្លាំង ក្នុងកាលនៃអ្នកមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់អ្នកក្រៃលែងជាងប្រថពីដែលទល់នឹងសមុទ្រទាំង ៤ ទៅទៀត ។*

*ពេលមេដំរីបានធ្វើព្រះពោធិសត្វនោះឲ្យរឹងមាំហើយ ទើបពោលថា បពិត្រអ្នកជាម្ចាស់ ឥឡូវនេះ ខ្ញុំនឹងនិយាយប្រាស្រ័យជាមួយក្តាមមាសនោះបន្តិច នឹងឲ្យគេដោះលែងអ្នក កាលនឹងអង្វរក្តាម មេដំរីទើបពោលគាថាទីបីថា*

**យេ កុឡីរា សមុទ្ទស្មឹំ, គង្គាយ យមុនាយ ច;**
**តេសំ ត្វំ វារិជោ សេដ្ឋោ, មុញ្ច រោទន្តិយា បតឹ។**

*ពួកក្តាមណា ដែលនៅក្នុងសមុទ្រក្តី ក្នុងទន្លេគង្គាក្តី យមុនាក្តី អ្នកជាសត្វទឹកប្រសើរជាងក្តាមទាំងនោះ សូមអ្នកមេត្តាលែងប្តី កាលដែលខ្ញុំកំពុងទួញយំរកប្តី សូមអ្នកមេត្តាលែងប្តី (របស់ខ្ញុំ) មកវិញ ក្នុងកាលឥឡូវនេះ ។*

*សេចក្តីក្នុងគាថានោះយ៉ាងនេះ គឺ ក្តាមពួកណាក្នុងមហាសមុទ្រក្តី ក្នុងទន្លេគង្គា ឬយមុនាក្តី លោកជាអ្នកប្រសើរជាងក្តាមទាំងអស់នោះ ដោយការដល់ព្រមដោយវណ្ណៈ និងភាពជាធំ ដោយហេតុនោះ ខ្ញុំទើបសូមអង្វរលោក សូមលោកមេត្តាលែងប្តីរបស់ខ្ញុំដែលកំពុងស្រែកនោះ ។*

*កាលមេដំរីនោះកំពុងនិយាយ ក្តាមបានកាន់យកនិមិត្តបនៃសំឡេងស្ត្រី ជាអ្នកមានចិត្តញាប់ញ័រ ទើបបន្ធូរតង្កៀបពីជើងដំរីពោធិសត្វ ដោយសម្គាល់ថា ដំរីនេះដែលយើងលែងហើយ នឹងធ្វើយ៉ាងនេះ ។ លំដាប់នោះ ដំរីលើកជើងជាន់ស្នូកក្តាម ធ្អឹងទាំងឡាយក៏បែកក្នុងទីនោះឯង ។ ដំរីពោធិសត្វស្រែកឡើងដោយសេចក្តីរីករាយ ដំរីទាំងអស់មកប្រជុំគ្នាហើយនាំយកមកនូវក្តាមដាក់ទុកលើគោក កាលជាន់ញាំញី ក៏បានធ្វើក្តាមឲ្យជាកម្ទេចតូចធំ ។*

តង្កៀបទាំងពីររបស់ក្តាមនោះបែកចេញពីសរីរៈ ហើយធ្លាក់ចុះក្នុងកន្ទែងមួយ ។ បឹងក្តាមនោះជាបឹងដែលជាប់នឹងទន្លេគង្គា ក្នុងកាលដែលទន្លេគង្គាពេញ ក៏ពេញទៅដោយទឹកក្នុងទន្លេគង្គា កាលទឹកទន្លេគង្គាតិច ទឹកក្នុងបឹងក៏ហូរចុះកាន់ទន្លេគង្គា ។

លំដាប់នោះ តង្កៀបក្តាមសូម្បីទាំងពីរនោះអណ្តែតទៅក្នុងទន្លេគង្គា ។ ក្នុងបណ្តាតង្កៀបក្តាមទាំងពីរនោះ តង្កៀបមួយបានចូលទៅកាន់សមុទ្រ មួយទៀត ត្រូវបានទៅបងប្អូនព្រះរាជាទាំង ១០ អង្គ (ទសារហៈ) ដែលកំពុងលេងទឹក ហើយធ្វើជាស្គរឈ្មោះ **អាឡិង្គៈ**[១] ។ ចំណែកតង្កៀបមួយទៀត អណ្តែតហូរចូលទៅកាន់សមុទ្រ ពួកអសុរាទាំងឡាយបានកាន់យក ហើយធ្វើជាស្គរឈ្មោះ **អាលម្ពរៈ** ។ ក្នុងកាលជាក្រោយមក ពួកអសុរានោះ ត្រូវសក្កទេវរាជបានឲ្យចាញ់ហើយ ទើបបោះចោលនូវស្គរនោះហើយរត់ទៅ ។ គ្រានោះ ស្តេចសក្កៈ ក៏គេកាន់យកដើម្បីប្រយោជន៍ខ្លួន ។ អាចារ្យទាំងឡាយសំដៅយកស្គរនោះ ពោលថា ស្គរអាលម្ពរៈគ្រហឹមដូចផ្គរលាន់ ។

ព្រះសាស្តាបាននាំយកព្រះធម្មទេសនានេះមកហើយទ្រង់ក៏ប្រកាសសច្ចធម៌ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃការប្រកាសសច្ចធម៌ ប្តីប្រពន្ធទាំងពីរ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។

**តទា ការេណុកា អយំ ឧបាសិកា អហោសិ** មេដំរីក្នុងកាលនោះបានមកជាឧបាសិកានេះ ។

**វារណោ បន អហមេវ អហោសិំ** ចំណែកដំរីនោះ បានមកជាតថាគតនេះឯង ។

**សុវណ្ណកក្កដកជាតកំ និដ្ឋិតំ ។**

---

[១] ក្នុងសារត្ថប្បកាសិនី អដ្ឋកថាសុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ឱបម្មសំយុត្ត អាណិសូត្រ ពោលថា ស្គរនោះឈ្មោះ អានកៈ ។

*សុវណ្ណកក្កដកជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត បទុមវគ្គ បិដលេខ ៥៨ ទំព័រ ១៥៣)*

# អង្គប្រកបរបស់ក្តាមមាន ៦ យ៉ាង

| | | |
|---|---|---|
| **សិង្គីមិគោ** | *ម្រឹគមានសម្បុរដូចមាស* | **កក្កដកះ , កុឡីរះ** *ប្រែថា ក្តាម* |
| **អាយតចក្ខុនេត្តោ** | *ជាសត្វមានភ្នែកលៀនវែង* | |
| **អដ្ឋិត្តចោ** | *មានឆ្អឹងជាស្បែក* | |
| **វារិសយោ** | *ជាសត្វនៅក្នុងទឹក* | |
| **អលោមោ** | *មិនមានរោម* | |

*ថ្ងៃ អាទិត្យ ១១ កើត ខែ អស្សុជ ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១ ម.ស. ១៩៣៩ ច.ស. ១៣៧៩ ត្រូវនឹងថ្ងៃទី ០១ ខែ កញ្ញា គ.ស. ២០១៧*

*ដោយ ស.ដ.វ.ថ.*